# ឌុច បដិសេធថា «ជនរស់រានមានជីវិត»ម្នាក់ទៀត មិនត្រូវបានឃុំខ្លួននៅមន្ទីរស-២១ទេ

*ដោយ ឡូរ៉ា ម៉ាកដូណល់*

*ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

នៅក្នុងថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមដំណើរការដោយប្រកាសលុបចោលឈ្មោះសាក្សីម្នាក់ទៀតចេញពីបញ្ជីឈ្មោះសាក្សី ដែលត្រូវឡើងមកធ្វើសក្ខីកម្មនៅក្នុងអង្គជំនុំជម្រះកាត់ទោសជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ បន្ទាប់ពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ំ ដែលបង្ហាញពីហេតុការណ៍ថ្មីៗមួយចំនួនទាក់ទិននឹងគុកទួលស្លែង (មន្ទីរស-២១) មក ខ្ញុំរំពឹងថា ចៅក្រមនឹងបង្កើនបទដ្ឋានរបស់ខ្លួនបន្ថែមទៀត ហើយជាមួយគ្នានេះសាក្សីជាច្រើនទៀតក៏នឹងត្រូវដកចេញពីបញ្ជីឈ្មោះសាក្សីផងដែរ ។

កាលពីសប្តាហ៍មុនបន្ទាប់ពីការធ្វើសក្ខីកម្មរបស់ នង ចាន់ផល ក្មេងដែលនៅរស់រានជីវិតពីមន្ទីរស-២១ មក ឌុច បានអះអាងថា នង ចាន់ផល មិនមែនជាអ្នកទោសមន្ទីរស-២១ឡើយ ពីព្រោះក្មេងៗទាំងអស់ត្រូវបានសម្លាប់ចោលដោយយោងទៅតាមគោលនយោបាយរបស់បក្ស ហើយគ្មានក្មេងណាម្នាក់អាចគេចផុតបានទេ ។ ឌុច បានកត់សម្គាល់ឃើញថាគ្មានឯកសារណាមួយបង្ហាញថា នង ចាន់ផល និងម្តាយរបស់គាត់បានមកដល់មន្ទីរស-២១ឡើយ ។ ការជំទាស់របស់ ឌុច បានធ្វើឡើងនៅពេលរសៀលដែលធ្វើឲ្យភាគីនៅក្នុងអង្គសវនាការទាំងអស់ មានភាពភ្ញាក់ផ្អើលយ៉ាងខ្លាំង រួមទាំងចៅក្រមផងដែរ ។ ថ្ងៃនេះ មេធាវីការពារក្តីបានប្រើប្រាស់វិធីសាស្ត្រថ្មីដោយប្រកាសនៅចំពោះមុខសាក្សីថា ឌុច បានជំទាស់នឹងការអះអាងដែលថាសាក្សីគឺជាអ្នករស់រានមានជីវិតពីមន្ទីរស-២១ មុននឹងសាក្សីចាប់ផ្តើមធ្វើសក្ខីកម្ម ។ មេធាវីការពារក្តីបាននិយាយថា ខ្លួនបានជម្រាបពីការជំទាស់នេះមុន ដើម្បីឲ្យចៅក្រម និងភាគីផ្សេងទៀតអាចសួរសំណួរដែលពាក់ព័ន្ធគ្នា ។ លោកប្រធានចៅក្រមបានច្រានចោលសេចក្តីណែនាំនេះដោយឆ្លើយតបថា មេធាវីការពារក្តីអាចមានឱកាសត្រួតពិនិត្យលើសក្ខីកម្មរបស់ លី ហ៊ំ ក្នុងអំឡុងពេលសួរសំណួរបាន ។ យ៉ាងណាមិញ ក្រោយពីការត្រួតពិនិត្យរបស់លោកប្រធានលើសាក្សីមក ចៅក្រមបានសួរសំណួរជាច្រើនដើម្បីសន្និដ្ឋានថាតើ លី ហ៊ំ ពិតជាអ្នកទោសមន្ទីរស-២១មែនដែរឬទេ ។

លី ហ៊ា អាយុ៥៧ឆ្នាំ មិនយល់ពីសំណួរដែលចៅក្រមបានសួរមកគាត់ និងមានផលវិបាកក្នុងការរៀបរាប់ពីហេតុការណ៍ដែលកើតមានឡើងក្នុងអំឡុងឆ្នាំ១៩៧៥រហូតដល់១៩៧៩ ។ ក្រោយពីឈប់ចូលបំរើកងទ័ពខ្មែរក្រហម ហើយត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៥មក លី ហ៊ា បានជាប់ឃុំនៅក្នុងអគារឃុំឃាំងចំនួនបួនកន្លែងគឺ មន្ទីរសន្តិសុខ១៥ មន្ទីរពេទ្យឆ្កួត តាខ្មៅ មន្ទីរស-២១ និងកន្លែងកសាងខ្លួនព្រៃសដែលស្គាល់ថា មន្ទីរស-២៤ ។ លី ហ៊ា ហាក់បីដូចជាមានភាពស្រពិចស្រពិលនៅក្នុងសក្ខីកម្ម និងការចងចាំរបស់គាត់ដែលស្តីពីការជាប់ឃុំឃាំងបន្តបន្ទាប់នៅក្នុងមន្ទីរឃុំឃាំងទាំងនេះ ។ នៅមន្ទីរពេទ្យឆ្កួត តាខ្មៅ លី ហ៊ា បញ្ជាក់ថា គាត់ត្រូវបានសួរចម្លើយចំនួនបីដង និងបានទទួលរងការវាយធ្វើបាបដើម្បីឲ្យឆ្លើយសារភាពមុននឹងត្រូវបញ្ជូនទៅកាន់មន្ទីរស-២១ ដែលនៅទីនោះគាត់ត្រូវបានសួរចម្លើយតែម្តងទេ ។ លី ហ៊ា បានចំណាយពេលអស់ប្រហែលមួយខែនៅមន្ទីរស-២១ មុននឹងគាត់ត្រូវបានបញ្ជូនមកកាន់មន្ទីរស-២៤ ដែលក្រោយមកគាត់បានលួចរត់ដោយហែលទឹកឆ្លងស្ទឹង ។

ខុសពីសក្ខីកម្មរបស់អ្នករស់រានមានជីវិតទាំងបួនរូប ដែលបានឡើងធ្វើសក្ខីកម្មកាលពីសប្តាហ៍មុនដោយផ្តល់នូវព័ត៌មានស្របគ្នាមួយនៅក្នុងដំណើរការនីតិវិធី សក្ខីកម្មរបស់ លី ហ៊ា មានលក្ខណៈខុសប្លែកពីគេបន្តិច ។ លី ហ៊ា មិនអាចចាំបានថា គាត់ត្រូវបានគេថតរូបមុននឹងចូលទៅដល់មន្ទីរស-២១នោះទេ ។ គាត់និយាយថា គាត់មិនទទួលបានលេខសម្គាល់ខ្លួនអ្នកទោសឡើយ ។ គាត់បន្ថែមទៀតថា គាត់ទទួលបានការវ៉ូតទឹកសម្អាតខ្លួនចំនួនបីដងក្នុងមួយសប្តាហ៍នៅខាងក្រៅបន្ទប់ឃុំឃាំង ដោយមានការដោះខ្នោះចេញ ។ នៅពេលជាប់ឃុំ លី ហ៊ា ត្រូវបានអនុញ្ញាតឲ្យពាក់សម្លៀកបំពាក់របស់ខ្លួន ។ គាត់ទទួលបានបាយ ឬស៊ុបហូបពីរដងក្នុងមួយថ្ងៃ ។ គាត់បានរៀបរាប់ថា អ្នកយាមគឺជាមនុស្សគួរឲ្យខ្លាច ប៉ុន្តែមានអ្នកយាមម្នាក់បានឲ្យថ្នាំព្យាបាលជម្ងឺមកគាត់ ។ លី ហ៊ា មិនទទួលរងការធ្វើទារុណកម្មឡើយ បើទោះបីជាគាត់ត្រូវបានអ្នកយាមគុកវាយ នៅពេលដែលគាត់ធ្វើឲ្យក្រពប់ធុងដាក់ទឹកនោមរបស់អ្នកទោសនៅក្នុងបន្ទប់ឃុំខ្លួនរបស់គាត់ក៏ដោយ ។ បន្ថែមលើនេះ លី ហ៊ា បានរៀបរាប់ថា នៅពេលដែលមានមនុស្សស្លាប់ សាកសពត្រូវបាននាំចេញពីបន្ទប់ឃុំឃាំងភ្លាមៗតែម្តង ។ នីតិវិធីនិងលក្ខខណ្ឌទាំងអស់នេះ មានលក្ខណៈមនុស្សធម៌ជាងហេតុការណ៍ដែលបានរៀបរាប់ម្តងហើយម្តងទៀត នៅក្នុងសក្ខីកម្មដែលបានធ្វើឡើងកន្លងមក ។ លី ហ៊ា បាននិយាយថា គាត់ដឹងថាគាត់ពិតជាបានជាប់ឃុំឃាំងនៅមន្ទីរស-២១មែនពីព្រោះអ្នកយាមគុកបានប្រាប់គាត់ថាគាត់នៅមន្ទីរស-២១ ។

បន្ថែមលើភាពច្របូកច្របល់នៃសក្ខីកម្មរបស់ លី ហ៊ា ឯកសារដែលប្រើប្រាស់ដោយចៅក្រមដើម្បីត្រួតពិនិត្យលើសាក្សីរូបនេះដែលរួមមានប្រវត្តិរូបសង្ខេប និងចម្លើយសារភាពទាំងអស់គឺសុទ្ធតែជាភាសាខ្មែរ ។ លើសពីនេះ ឯកសារទាំងនេះខ្វះខាតនូវប្រភពព័ត៌មានដើម ហើយត្រូវបានប្រគល់ឲ្យដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការមិនទទួលផលប្រយោជន៍ប្រចាំនៅទីក្រុងភ្នំពេញ ។ បើទោះបីជាឯកសារភាគច្រើនត្រូវបានប្រគល់ឲ្យ អ.វ.ត.ក ដោយមានភ្ជាប់ជាមួយនឹងពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏ លី ហ៊ា បានបង្កើតឲ្យមានភាពច្របូកច្របល់ពីប្រភពដើមនៃឯកសារទាំងនោះថាតើនរណាជាអ្នកសរសេរនៅលើឯកសារនេះ និងថាតើគាត់ទទួលបានឯកសារទាំងនេះមកពីណាមុននឹងចូលមកធ្វើសក្ខីកម្ម ។ អាឡាំង វែនណឺ មេធាវីរបស់ លី ហ៊ា បានស្នើសុំឲ្យមានការអានឯកសារទាំងនេះនៅក្នុងអង្គសវនាការ ។ បន្ទាប់មក ស៊ីលយ៉ា ខាតរ៉ាយ៍ បានស្តីបន្ទោសឲ្យ អាឡាំង វែនណឺ ថា មិនបានផ្តល់នូវឯកសារផ្គត់ផ្គង់ឲ្យបានគ្រប់គ្រាន់លោកស្រីក៏បានសួរទៅ អាឡាំង វែនណឺ ថាតើលោកយល់ស្របដែរឬទេដែរថា“សាក្សីមិនបានត្រៀមខ្លួន” ។ វែនណឺ បានពន្យល់ថាមានបញ្ហាការបកប្រែបានកើតឡើង ប៉ុន្តែលោកក៏បានជួបជាមួយនឹងសាក្សីចំនួនបីដងមុននឹងធ្វើសក្ខីកម្មដែរ ។ ស៊ីលយ៉ា ខាតរ៉ាយ៍ បាននិយាយថាលោកស្រី និងចៅក្រមទាំងអស់សង្ឃឹមថាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នឹងមានការត្រៀមខ្លួនឲ្យកាន់តែប្រសើរជាងមុន ។

ចៅក្រម ឡាវែន៍ បានលើកឡើងពីបញ្ហាប្រភពដើមនៃឯកសារ ហើយ វែនណឺ បាននិយាយថាលោកអាចបង្ហាញនូវឯកសារជាលាយលក្ខអក្សរដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា បញ្ជាក់ថាឯកសារនេះពិតជាមានប្រភពចេញពីមន្ទីរស-២១មែន ។ បន្ទាប់មកទៀត មេធាវីការពារក្តីបានសួរនូវសំណួរមួយចំនួនស្តីពីទំនាក់ទំនងរបស់ លី ហ៊ា ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដូចគ្នានឹងការសួរសំណួរទៅកាន់ នួន ចាន់ផល វិធីសាស្រ្តសួរសំណួររបស់មេធាវីការពារក្តីមកលើ លី ហ៊ា បានឆ្លុះបញ្ចាំងឲ្យឃើញថាមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគល់ប្រវត្តិរូបសង្ខេបទៅឲ្យ លី ហ៊ា ដែលផ្តល់ជាគំនិតមួយដែលថា លី ហ៊ា ពិតជាជាប់ឃុំនៅមន្ទីរស-២១ ។ ប៉ុន្តែតាមពិតទៅ លី ហ៊ា បានជាប់ឃុំនៅគុកមួយផ្សេងទៅវិញទេ ។ ជាច្រើនដង មេធាវីការពារក្តីហាក់បីដូចជាចង់លើកឡើងពីលទ្ធភាពដែលថាមជ្ឈមណ្ឌលឯកសារកម្ពុជាអាចធ្វើឲ្យមានភាពលំអៀងនៅក្នុងដំណើរការនីតិវិធី ។ ដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជាបានចំណាយពេលជាងដប់ពីរឆ្នាំ ដើម្បីស្វែងរកឯកសាររាប់ពាន់ទាក់ទិននឹងសម័យខ្មែរក្រហម នោះឯកសារមួយភាគធំដែលដើរតួយ៉ាងសំខាន់នៅក្នុងអង្គជំនុំជម្រះកាត់ទោស ឌុច ត្រូវបានប្រគល់ឲ្យដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដូច្នេះ ប្រសិនបើមានភស្តុតាងបញ្ជាក់ពីបញ្ហា

នេះមែននោះ ការចោទប្រកាន់ពីភាពលំអៀងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមេធាវីការពារក្ដីអះអាងខាងលើអាចនឹងមានផលប៉ះពាល់ខ្លាំងមកលើដំណើរការនីតិវិធីរបស់តុលាការ ។ ប៉ុន្តែតាមការយល់ដឹងរបស់ខ្ញុំ គ្មានភស្តុតាងណាមួយបានបញ្ជាក់ថាការចោទប្រកាន់របស់មេធាវីការពារក្ដីពីភាពលំអៀង និងការជ្រៀតជ្រែករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាការពិតនោះទេ ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍ពីដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះគឺកើតឡើងនៅពេលដែល ឌុច ត្រូវបានផ្ដល់ឱកាសឲ្យធ្វើការឆ្លើយតបនឹងសក្ខីកម្មរបស់ លី ហ៊ា ។ បន្ទាប់ពីការសួរ និងឆ្លើយសំណួរដ៏ច្របូកច្របល់ដែលមើលទៅគ្មាននរណាម្នាក់ដឹងថាមានអ្វីកំពុងតែកើតឡើងនោះមក ឌុច បានក្រោយឈរធ្វើការឆ្លើយតបដោយមានភាពជឿជាក់នៅក្នុងចិត្ត ។ ឌុច បានអះអាងថាឯកសារខ្លះមានប្រភពចេញពីមន្ទីរស-២១មែន ពីព្រោះថាគាត់ស្គាល់អក្សរកត់ត្រារបស់អ្នកនៅក្រោមបង្គាប់របស់គាត់ដែលសរសេរនៅលើឯកសារទាំងនោះ ។ ឌុច បានចង្អុលបង្ហាញថា “អ៊ា ហ៊ា” ឈ្មោះប្រហាក់ប្រហែលនឹង លី ហ៊ា ដែលបានមកដល់មន្ទីរស-២១មុនឆ្នាំ១៩៧៩ មានចុះក្នុងបញ្ជីអ្នកទោសមន្ទីរស-២១ដែលត្រូវ“កម្ទេច” ។ ប៉ុន្តែមានឯកសារមួយទៀតបានអះអាងថា “អ៊ា ហ៊ា”នេះត្រូវបានដោះលែង ។ ឌុច បានគូសបញ្ជាក់ថាគ្មាននរណាត្រូវបានដោះលែងនោះទេ ប៉ុន្តែមានតែបញ្ជីដោះលែងក្លែងបន្លំដែល ណាត អតីតប្រធានមន្ទីរស-២១បានប្រឌិតឡើង ដើម្បីបិទបាំងការសម្លាប់អ្នកទោសដោយគ្មានការអនុញ្ញាតតែប៉ុណ្ណោះ ។ ឌុច បាននិយាយថា“យោងតាមឯកសារទាំងអស់នេះ សមមិត្ត អ៊ា ហ៊ា បានស្លាប់ហើយ” ។ ដោយផ្អែកលើបទពិសោធន៍ជាគ្រូគណិតវិទ្យា ឌុច បានធ្វើការបន្ថែមនិងបន្ថយព័ត៌មានដោយកត់សម្គាល់ថាអាយុរបស់ “អ៊ា ហ៊ា” ដែលចុះក្នុងប្រវត្តិរូបអ្នកទោសមិនដូចគ្នានឹងអាយុរបស់ លី ហ៊ា នៅពេលទៅដល់មន្ទីរស-២១ឡើយ ។ ឌុច បានទទួលស្គាល់ថា លី ហ៊ា បានទទួលរងការឈឺចាប់ និងការធ្វើទារុណកម្មមែន ប៉ុន្តែមិនមែននៅមន្ទីរស-២១ទេ ។

បញ្ជីឈ្មោះអ្នកទោសបានគូសបញ្ជាក់ថា អ៊ា ហ៊ា បានមកដល់មន្ទីរស-២១នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ។ នៅពេលដែលមេធាវីការពារក្ដីសួរ លី ហ៊ា ថា គាត់នៅទីណាតាមកាលបរិច្ឆេទខាងលើ គាត់បានឆ្លើយថា គាត់នៅផ្ទះក្នុងភូមិរបស់គាត់ ។ មេធាវីរបស់ លី ហ៊ា មិនបានបញ្ជាក់ឬបដិសេធថាឈ្មោះ អ៊ា ហ៊ា ដែលមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសគឺជាឈ្មោះ អ៊ា ហ៊ា ដែលចុះនៅក្នុងប្រវត្តិរូបនិងចម្លើយសារភាព ដែលអង្គជំនុំជម្រះយកឯកសារនេះជាឯកសារយោងសម្រាប់ដំណើរនីតិវិធីក្នុងថ្ងៃនេះឡើយ ។

នៅក្នុងថ្ងៃនេះ គ្មានភាគីណាមួយសួរពីគោលបំណងរបស់ លី ហ៊ិ ឡើយ ។ ភាគីទាំងអស់ហាក់បីដូចជាចាត់ទុក លី ហ៊ិ ជាជនរងគ្រោះដែលមានបញ្ហាតានតឹងផ្លូវចិត ហើយកំពុងតែព្យាយាមរៀបរាប់ពីអ្វីដែលបានកើតឡើងចំពោះគាត់កាលពីសាមសិបឆ្នាំមុន ។ បើទោះបីជាសក្ខីកម្មរបស់ លី ហ៊ិ អាចបង្ហាញពីលទ្ធភាពដែលអាចរត់រួចពីមន្ទីរស-២៤ និងលទ្ធភាពដែលអាចត្រូវបានដោះលែងចេញពីមន្ទីរស-២១ និងស-២៤ក៏ដោយ ក៏យើងមិនដឹងថាតើចៅក្រមគិតថាសក្ខីកម្មរបស់ លី ហ៊ិ មានសារសំខាន់ប៉ុណ្ណានោះទេ ។